ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គោលការណ៍ណែនាំសម្រាប់អនុវត្តយន្តការ រាយការណ៍ និងការឆ្លើយតបចំពោះការ អាក់ជាយ និងការរើសអើងទាក់ទងនឹង មេរោគអេដស៍ ឆ្នាំ២០២៤-២០២៨

ខែធ្នូ ឆ្នាំ២០២៤

អារម្ភកថា

ប្រទេសកម្ពុជាបានចោះដំហានយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០។ ប្រទេសយើងក៏បានទទួលជោគជ័យក្នុងការទប់ស្កាត់ការរីករាលដាលទាន់ពេលវេលា ពង្រីកលទ្ធភាពផ្តល់ការព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍(PLHIV)បានយ៉ាងទូលំទូលាយ និងសម្រេចបានការកាត់បន្ថយនូវការឆ្លងថ្មីគួរឱ្យកត់សម្គាល់។ ទោះបីជាយ៉ាងនេះក្តី ដើម្បីឱ្យសម្រេចបាននូវគោលដៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥ យើងត្រូវការដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលក្នុងនោះការមាក់ងាយនិងការរើសអើងជាផ្នែកមួយដ៏សំខាន់បំផុតនៃបញ្ហាទាំងនោះ។

គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់កម្ពុជាបានទទួលស្គាល់បញ្ហាប្រឈមទាំងនេះ។ គោលនយោបាយនេះផ្តោតលើការដោះស្រាយមូលហេតុជាឫសគល់នៃការមាក់ងាយនិងការរើសអើងដោយ ១- គាំទ្រ និងលើកទឹកចិត្តអ្នកតំណាងអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ(KPs) និងសហគមន៍ងាយរងគ្រោះឱ្យចូលរួមក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ២- ផ្តល់ការគាំទ្រផ្នែកគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍និងប្រជាជនគន្លឹះ និងផ្តល់សិទ្ធិអំណាចដល់ពួកគាត់ក្នុងការស្វែងរកការគាំទ្រដើម្បីបញ្ចប់ការមាក់ងាយនិងការរើសអើង។

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ឆ្នាំ២០២៤-២០២៨មានទស្សនវិស័យថា៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍និងជំងឺអេដស៍ និងគ្មានការមាក់ងាយនិងការរើសអើង។

ផែនការសកម្មភាពទាក់ទងនឹងការមាក់ងាយនិងការរើសអើងត្រូវបានបង្កើតឡើង និងប្រើជាផែនទីបង្ហាញផ្លូវដើម្បីឱ្យសម្រេចតាមចក្ខុវិស័យខាងលើនេះ។ ដោយទទួលស្គាល់នូវសមិទ្ធផលកន្លងមក និងសង្កត់ធ្ងន់លើតម្រូវការក្នុងការដោះស្រាយឧបសគ្គនានាដែលនៅសេសសល់ទាក់ទងនឹងសិទ្ធិមនុស្ស។ ផែនការនេះស្របតាមការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផ្អែកតាមសេចក្តីប្រកាសនយោបាយជាសកលឆ្នាំ២០២១ ស្តីពីមេរោគអេដស៍និងជំងឺអេដស៍ និងលើកកម្ពស់ការប្រើប្រាស់ជំនាញ និងការគាំទ្រពីភាពជាដៃគូសកលលើសកម្មភាពដើម្បីលុបបំបាត់គ្រប់ទម្រង់នៃការមាក់ងាយនិងរើសអើងទាក់ទងនឹងមេរោគអេដស៍។

ផែនការសកម្មភាពនេះផ្តល់អាទិភាពដល់សុខុមាលភាពរបស់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងសហគមន៍នានាជាការចាំបាច់ដើម្បីឱ្យការអនុវត្តផែនការនេះទទួលបានជោគជ័យ។

ខ្ញុំសូមធ្វើការអំពាវនាវដល់អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា និងសហគមន៍ សូមធ្វើការរួមគ្នា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាពនិងការអត់ឱនឱ្យបានទូទាំងប្រទេស។ យើងត្រូវតែទទួលស្គាល់ផលប៉ះពាល់យ៉ាងជ្រាលជ្រៅនៃការរើសអើង ដែលបង្កើតឧបសគ្គដល់ការអប់រំ ការថែទាំសុខភាព និងការងារ ហើយនៅទីបញ្ចប់នាំទៅរកភាពក្រីក្រនិងវិសមភាព។ ក្នុងន័យនេះ ធន្ធៈនយោបាយ

ដ៏រឹងមាំ សង្គមស៊ីវិលដ៏ស្វាហាប់ និងការចូលរួមប្រកបដោយអត្ថន័យរបស់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ គឺជាកត្តាសំខាន់សម្រាប់ការអនុវត្តផែនការនេះប្រកបដោយជោគជ័យ។ យើងទាំងអស់គ្នាមានការទទួលខុសត្រូវចំពោះការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ការសម្របសម្រួលគាំទ្រក្នុងស្រុក និងការចូលរួមយ៉ាងសកម្មពីប្រជាជនកម្ពុជាទាំងអស់ដើម្បីបញ្ចប់ការមាក់ងាយនិងការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ។

តាមរយៈការដោះស្រាយការមាក់ងាយ និងការរើសអើងទាំងនៅកន្លែងថែទាំសុខភាព សហគមន៍ ការអប់រំ និងផ្នែកសំខាន់ៗផ្សេងទៀត យើងអាចបង្កើតបរិយាកាសមួយ ដែលបុគ្គលម្នាក់ៗមានអារម្មណ៍ថាមានសិទ្ធិអំណាចក្នុងការទៅចូលប្រើសេវាកម្មតាមតម្រូវការ។ យើងរួមគ្នាកសាងកម្ពុជាមួយដែលគ្មានជំងឺអេដស៍។

ឧេសរដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង-មូលី

មាតិកា

សេចក្តីផ្តើម ៣
តើយន្តការរាយការណ៍ និងឆ្លើយតបការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ៤
តើគោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់នរណាខ្លះ? ៥
តើអ្នកណាខ្លះអាចដាក់ពាក្យរាយការណ៍/ការតវ៉ា ការមាក់ងាយ និងរើសអើង ៥
លំហូរយន្តការរាយការណ៍ និងការឆ្លើយតបការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ... ៦
ក្របខណ្ឌពេលវេលានៃការឆ្លើយតប ៨
សមាសភាព និងទំនួលខុសត្រូវរបស់ក្រុមឆ្លើយតប ៨
ការដាក់ពាក្យរាយការណ៍/ការតវ៉ា អំពីការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ១១
ការទទួលពាក្យរាយការណ៍/ការតវ៉ា អំពីការមាក់ងាយ និងការរើសអើង ១១
វិធានការក្រុមឆ្លើយតប ១២
ការតាមដានបន្តជាមួយពាក្យរាយការណ៍/ការតវ៉ា ១៣
ភាពសម្ងាត់ និងការភ័យខ្លាចចំពោះការសងសឹក ១៤
ការផ្សព្វផ្សាយយន្តការរាយការណ៍ និងឆ្លើយតបចំពោះការមាក់ងាយ និងការរើសអើង ១៤
ការកត់ត្រាទុកជាឯកសារ និងការរក្សាកំណត់ត្រា ១៥
ការតម្រង់ទិស និងការកសាងសមត្ថភាពក្រុមឆ្លើយតប HIVSD ១៥
ការត្រួតពិនិត្យតាមដានក្រុមឆ្លើយតបការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ១៥
ឧបសម្ព័ន្ធទី ១ – ទម្រង់ព័ត៌មានឧបទ្ធរហេតុ ១៦
ផលវិបាក និងសកម្មភាពតាមដានបន្ត ១៨
ឧបសម្ព័ន្ធទី ២ – របាយការណ៍អង្កេត HIVSD ២០
សង្ខេបការអង្កេត និងលទ្ធផល ៖ ២០
ឧបសម្ព័ន្ធទី ៣ – ព័ត៌មានទំនាក់ទំនងនៃអង្គការជំនួយផ្នែកច្បាប់ ២១

ពាក្យចំណេញ

CBO	Community-based organizations	អង្គការសហគមន៍
CLM	Community-led monitoring	ការតាមដានដឹកនាំដោយសហគមន៍
CPN+	Cambodian PLHIV Network	បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា
CSO	Civil society organizations	អង្គការសង្គមស៊ីវិល
FEW	Female entertainment worker	ស្ត្រីធ្វើការនៅសេវាកម្សាន្តសប្បាយ
FHI 360	Family Health International 360	អង្គការសុខភាពគ្រួសារអន្តរជាតិ ៣៦០
FONPAM	Joint Forum of Networks of PLHIV and MARPs	វេទិការួម និងបណ្តាញនៃអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនប្រឈមមុខខ្ពស់
HACC	Health Action Coordinating Committee	គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព
HIV	Human Immunodeficiency Virus	មេរោគដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស
HIVSD	HIV-Related Stigma and Discrimination	ការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍
KP	Key Population	ក្រុមប្រជាជនគន្លឹះ (ក្រុមប្រឈមខ្ពស់)
LGBT	Lesbian, Gay, Bisexual and Transgender People	ស្រីស្រឡាញ់ស្រីដូចគ្នា ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកបំប្លែងភេទ
MoEYS	Ministry of Education, Youth and Sports	ក្រសួងអប់រំ យុវជន និងកីឡា
MoI	Ministry of Interior	ក្រសួងមហាផ្ទៃ
NAA	National AIDS Authority	អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
NCHADS	National Center for HIV/AIDS, Dermatology and STD	មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
OW	Outreach Worker	អ្នកចុះអប់រំផ្ទាល់
PLHIV	People Living with HIV	អ្នករស់នៅជាមួយមេរោគអេដស៍

សេចក្តីផ្តើម

វិសមភាពក្នុងការទទួលបានសេវាធ្វើតេស្ត និងព្យាបាលមេរោគអេដស៍ ដោយសារតែការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ (HIVSD) នៅតែជាបញ្ហាប្រឈមដ៏សំខាន់មួយដែលរារាំងអ្នកផ្ទុកមេរោគអេដស៍ (PLHIV) ពីការដឹងស្ថានភាពមេរោគអេដស៍របស់ពួកគេ និងការទទួលបានសេវាដែលពួកគេត្រូវការ។ របកគំហើញពីសន្ទស្សន៍ស្តីពីការមាក់ងាយ ២.០ ដែលបានធ្វើឡើងកាលពីឆ្នាំ២០១៩ ដោយបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា (CPN+) បង្ហាញថាការមាក់ងាយ និងការរើសអើងក្នុងការថែទាំសុខភាពបានកើតមាន ហើយក្រុមប្រឈមមុខខ្ពស់ (KPs) បានប្រឈមមុខនឹងការមាក់ងាយ និងការរើសអើងស្រដៀងគ្នានៅក្នុងបរិបទផ្សេងៗគ្នា ដូចជាការបន្តុះបង្អាប់នៅសាលារៀន និងអំពើហិង្សាក្នុងគ្រួសារនិងផ្លូវភេទចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ ឧបទ្ទវហេតុទាំងនេះមិនត្រឹមតែរារាំងបុគ្គលមិនឱ្យចូលរួម និងទទួលបានសេវាដែលពួកគេត្រូវការដើម្បីថែរក្សាសុខភាពឱ្យបានល្អ និងមានសុវត្ថិភាពប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបង្កឱ្យមានការមាក់ងាយខ្លួនឯង និងឧបសគ្គស្ថាប័ន ដែលរារាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការបញ្ចប់ជំងឺអេដស៍ទៀតផង។

កម្ពុជាប្តេជ្ញាបញ្ចប់ជំងឺអេដស៍ ជាការគំរាមកំហែងសុខភាពសាធារណៈមួយត្រឹមឆ្នាំ២០២៥ ជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ សេចក្តីថ្លែងការណ៍នយោបាយឆ្នាំ២០២១ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ បញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់ប្រទេស ចំពោះការឆ្លើយតបនឹងជំងឺអេដស៍ផ្អែកលើសិទ្ធិ និងការប្តេជ្ញាចិត្តថ្មីរបស់ពួកគេក្នុងការបញ្ចប់វិសមភាពដែលជំរុញឱ្យមានការរីករាលដាលនៃមេរោគអេដស៍។ តាមរយៈការដាក់បញ្ចូលគោលដៅថ្មីនៃយុទ្ធសាស្ត្រឆ្លើយតបនឹងជំងឺអេដស៍សកល ដែលមានចំណុចដៅកត្តាជំរុញសង្គម ១០-១០-១០ កម្ពុជាបានទទួលស្គាល់ថាការដោះស្រាយសិទ្ធិមនុស្ស យេនឌ័រ និងជាពិសេសការមាក់ងាយ និងការរើសអើង គឺជាគន្លឹះក្នុងការបញ្ចប់វិសមភាព និងជំងឺអេដស៍ត្រឹមឆ្នាំ២០៣០ និងបានសន្យាលុបបំបាត់វិសមភាពទាំងនេះ។

ការរាយការណ៍/ការតវ៉ាពីការមាក់ងាយ និងការរើសអើង និងវិធានការសមស្រប/ទាន់ពេលវេលាដើម្បីឆ្លើយតបនឹងការរាយការណ៍/ការតវ៉ាទាំងនេះ គឺជាយុទ្ធសាស្ត្រគន្លឹះមួយចំនួនដើម្បីធានាបរិយាកាសអំណោយផលសម្រាប់បុគ្គលម្នាក់ៗក្នុងការទទួលបានសេវា និងកសាងទំនុកចិត្ត/ការទុកចិត្តរបស់សហគមន៍។ ការរាយការណ៍ដោយគ្មានវិធានការដោះស្រាយនោះ គឺជារឿងគ្មានន័យ និងធ្វើឱ្យបុគ្គលមិនចង់រាយការណ៍។ យន្តការតាមដានដែលដឹកនាំដោយសហគមន៍ (CLM) ដែលមានស្រាប់ ផ្តោតលើការកត់ត្រាទុកបទពិសោធន៍ ហើយយន្តការរាយការណ៍និងឆ្លើយតបចំពោះការមាក់ងាយ និងរើសអើងទាក់ទងនឹងមេរោគអេដស៍ដែលទើបបង្កើតថ្មី ផ្តល់ជម្រើសបន្ថែមមួយទៀតសម្រាប់អាជ្ញាធរ ដើម្បីស្វែងរកព័ត៌មានលម្អិតបន្ថែមលើការរាយការណ៍/ការតវ៉ាដែលបានដាក់ និងដើម្បីអង្កេត និងចាត់វិធានការដែលធ្វើឱ្យវាក្លាយជាយន្តការដ៏ទូលំទូលាយមួយដែលនឹងកសាងទំនុកចិត្តក្នុងចំណោមអ្នកផ្ទុកមេរោគ

អេដស៍ និងក្រុមប្រឈមមុខខ្ពស់ និងលើកទឹកចិត្តឱ្យមានការរាយការណ៍អំពីឧបទ្ទវហេតុនៃការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍ ដើម្បីលុបបំបាត់ឧបសគ្គដែលទាក់ទងនឹងបញ្ហានេះ ក្រៅពីសេវាមេរោគអេដស៍ និងនៅក្នុងបរិបទផ្សេងៗទៀត។ ការធានាថា សេវាមេរោគអេដស៍ត្រូវបានផ្តល់ជូនដោយគ្មានការមាក់ងាយ និងការរើសអើង អាចនឹងរួមចំណែកដល់ការសម្រេចបានគោលដៅ ៩៥-៩៥-៩៥ ត្រឹមឆ្នាំ២០២៥ ។

តើយន្តការរាយការណ៍ និងឆ្លើយតបការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍នៅកម្ពុជា គឺជាអ្វី?

យន្តការរាយការណ៍ និងការឆ្លើយតបការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ត្រូវបានបង្កើតឡើងដោយផ្អែកលើយន្តការតាមដានដែលដឹកដោយសហគមន៍ (CLM) ដែលមានស្រាប់ដែលបច្ចុប្បន្នកំពុងត្រូវបានអនុវត្តដោយ FoNPAM/DFoNPAM ដោយមានការគាំទ្រពី HACC, UNAIDS និង EpiC/FHI360 ហើយត្រូវបានប្រើប្រាស់ដើម្បីត្រួតពិនិត្យតាមដាន និងប្រមូលទិន្នន័យអំពីការឆ្លើយតបនឹងមេរោគអេដស៍នៅក្នុងខេត្តចំនួនប្រាំពីរក្នុងប្រទេសកម្ពុជា រួមមានខេត្តបន្ទាយមានជ័យ បាត់ដំបង កំពត រាជធានីភ្នំពេញ ព្រះសីហនុ សៀមរាប និងស្វាយរៀង។ ដោយដាក់សំណួរបន្ថែម ("តើអ្នកបានរាយការណ៍ពីឧបទ្ទវហេតុនេះពីមុនទេ? នៅកន្លែងណា?" និង "លេខទំនាក់ទំនងរបស់អ្នក") នៅក្នុងការស្ទង់មតិ CLM 7 ដែលផ្តោតលើការមាក់ងាយ និងការរើសអើង និងមុខងាររាយការណ៍អំពីការគ្រួញត្អែរ/ការតវ៉ា ក្រុមឆ្លើយតប HIVSD នៅក្នុងខេត្តនីមួយៗ ត្រូវបានប្រគល់ភារកិច្ចឱ្យស្វែងរកព័ត៌មានបន្ថែម និងចាត់វិធានការដោះស្រាយការគ្រួញត្អែរ/ការតវ៉ា HIVSD ដែលដាក់ដោយអ្នកផ្ទុកមេរោគអេដស៍និងក្រុមប្រឈមមុខខ្ពស់។ "ប្រអប់គូស" ដែលមានប្រយោគមួយថា "សូមគូសប្រអប់នេះ ប្រសិនបើអ្នកយល់ព្រមឱ្យគេទាក់ទងដើម្បីសាកសួរព័ត៌មានបន្ថែមអំពីការគ្រួញត្អែរ/ការតវ៉ានេះ (ប្រសិនបើត្រូវធ្វើការអង្កេត)" ត្រូវបានដាក់បន្ថែមទៅក្នុងការស្ទង់មតិ CLM ដើម្បីបង្ហាញថា ការយល់ព្រមត្រូវបានផ្តល់ឱ្យដោយអ្នកដាក់ការគ្រួញត្អែរ/ការតវ៉ា ហើយលេខទូរសព្ទទំនាក់ទំនងត្រូវបានផ្តល់ជូនដើម្បីទំនាក់ទំនងត្រឡប់មកវិញ។

នៅពេលដែលប្រអប់គូសនេះត្រូវបានជ្រើសរើស ការជូនដំណឹងត្រូវបានបញ្ជូនទៅកាន់ក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តដែលពាក់ព័ន្ធ តាមរយៈតេលេក្រាម ហើយការអង្កេត និងវិធានជាបន្តបន្ទាប់នឹងត្រូវធ្វើឡើងដោយសមាជិកក្រុមឆ្លើយតបសមស្រប។ ឯកសារសំណុំរឿងរួមទាំង "ទម្រង់ព័ត៌មានអំពីឧបទ្ទវហេតុ" (បំពេញដោយលេខាធិការដ្ឋានរបស់ក្រុមឆ្លើយតប សូមមើលឧបសម្ព័ន្ធទី ១) និង "របាយការណ៍អង្កេតឧបទ្ទវហេតុ" (បំពេញដោយសមាជិកក្រុមឆ្លើយតបដែលធ្វើការអង្កេត សូមមើលឧបសម្ព័ន្ធទី ២) នឹងត្រូវបញ្ជូនទៅ HACC ដើម្បីរក្សាទុកជាឯកសារបន្ទាប់ពីបញ្ចប់ការអង្កេត។ ការអង្កេតជួរទីមួយ តែងតែធ្វើឡើងដោយក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ហើយការតវ៉ាឬរាយការណ៍ទាំងឡាយណាដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្ត ឬត្រូវការអន្តរាគមន៍ពីអាជ្ញាធរថ្នាក់ខ្ពស់ នឹងត្រូវបញ្ជូន

ទៅក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ ដើម្បីអង្កេត និងចាត់វិធានការ។ ទិន្នន័យអំពីការឆ្លើយតបរបស់ CLM និង HIVSD នឹងត្រូវប្រើប្រាស់ដោយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីស្វែងរកការគាំទ្រសម្រាប់ការកែលម្អសេវា ដើម្បីលុបបំបាត់ការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ និងដើម្បីលើកកម្ពស់ការទទួលយកសេវាមេរោគអេដស៍កាន់តែច្រើនថែមទៀត។ គេគួរកត់សំគាល់ថា គោលបំណងនៃយន្តការរាយការណ៍ និងការឆ្លើយតប HIVSD មិនមែនគ្រាន់តែដើម្បីស្វែងរកយុត្តិធម៌ និងចាត់វិធានការចំពោះគ្រឹះស្ថាន ឬបុគ្គលដែលប្រព្រឹត្តនោះទេ ផ្ទុយទៅវិញ វាគឺជាឧបករណ៍មួយដើម្បីដោះស្រាយ HIVSD និងដើម្បីលើកកម្ពស់ការទទួលបានសេវាដោយការលុបបំបាត់ឧបសគ្គដែលមានចំពោះការទទួលសេវា។

តើគោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់នរណាខ្លះ?

គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងដើម្បីរៀបចំក្រុមឆ្លើយតប HIVSD ធ្វើការឆ្លើយតបទៅនឹងការរាយការណ៍/ការតវ៉ាអំពី HIVSD ដែលបានដាក់បញ្ជូនមកដោយសមាជិកសហគមន៍តាមរយៈវេទិកាអនឡាញ។ គោលការណ៍ណែនាំនេះ ក៏សម្រាប់ក្រុម និងបណ្តាញនានានៃអ្នកផ្ទុកមេរោគអេដស៍ និងបុគ្គលក្នុងក្រុមប្រឈមមុខខ្ពស់ ដែលជាផ្នែកមួយនៃវេទិការួមនៃបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ (FoNPAM) និងវេទិការួមនៃបណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខបំផុតថ្នាក់ស្រុកប្រតិបត្តិ (DFoNPAM) ជាលេខាធិការដ្ឋាននៃ FoNPAM ហើយ DFoNPAM នឹងដើរតួជាលេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត និងថ្នាក់ជាតិ។

តើអ្នកណាខ្លះអាចដាក់ពាក្យរាយការណ៍/ការតវ៉ា ការមាក់ងាយ និងរើសអើងទាក់ទងនឹងមេរោគអេដស៍?

យន្តការរាយការណ៍ និងការឆ្លើយតបការមាក់ងាយនិងរើសអើងទាក់ទងនឹងមេរោគអេដស៍ ត្រូវបានបង្កើតឡើងសម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងបុគ្គលដែលជាក្រុមប្រឈមមុខខ្ពស់ ដើម្បីដាក់ពាក្យរាយការណ៍/ការតវ៉ាអំពី HIVSD ផ្អែកលើវេទិកា CLM ដែលមានស្រាប់ ដែលបច្ចុប្បន្នកំពុងត្រូវបានអនុវត្តនៅក្នុងខេត្ត CLM ទាំងប្រាំពីរ ដោយមានផែនការពង្រីកបន្ថែមទៀត។ អ្នករស់នៅជាមួយផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ អាចស្កែន QR សម្រាប់ការស្ទង់មតិ CLM 7 ដោយប្រើទូរសព្ទចល័តរបស់ពួកគេ ដើម្បីដាក់ពាក្យរាយការណ៍/ការតវ៉ាសម្រាប់ធ្វើការអង្កេតនិងផ្តល់ការឃល់ព្រមដើម្បីទទួលព័ត៌មានអំពីលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើង។

លំហូរយន្តការរាយការណ៍ និងការឆ្លើយតបការអាក់ខាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍



១. អ្នកផ្តល់មេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ ស្កែន QR code សម្រាប់ការអង្កេត CLM survey 7 ដើម្បីដាក់ពាក្យរាយការណ៍/ការតវ៉ា HIVSD។

២. នៅពេលដែលប្រអប់គូស ត្រូវបានជ្រើសរើសនៅក្នុងការស្ទង់មតិ CLM 7 សារជាអក្សរមួយត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់លេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តដែលពាក់ព័ន្ធនៅក្នុងខេត្តប្រតិបត្តិការ CLM តាមរយៈ Telegram Chatbot។

៣. លេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីប្រមូលព័ត៌មានពីប្រវត្តិឧបទ្ទវហេតុ តាមរយៈទូរសព្ទ ឬដោយជួបផ្ទាល់។

៤. លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត សម្របសម្រួល និងចាត់តាំងសមាជិកក្រុមឆ្លើយតបសមស្របដើម្បីធ្វើការអង្កេតពាក្យរាយការណ៍/ការតវ៉ា។ ទម្រង់ "ព័ត៌មានអំពីឧបទ្ទវហេតុ" ត្រូវបានផ្តល់ជូនសមាជិកក្រុមឆ្លើយតបការអង្កេត។

៥. សមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ទាក់ទងគ្រឹះស្ថានដែលត្រូវបានចោទប្រកាន់ និង/ឬជនប្រព្រឹត្ត ដើម្បីអង្កេតពាក្យរាយការណ៍/ការតវ៉ា និងចាត់វិធានការ។

៦. សមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត បំពេញរបាយការណ៍អង្កេតឧបទ្ទវហេតុដោយបង្ហាញពីលទ្ធផល និងវិធានការដែលបានធ្វើឡើង ហើយបញ្ជូនសំណុំរឿងទៅកាន់លេខាធិការដ្ឋាន។

៧. លេខាធិការក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាដំបូង ដើម្បីផ្តល់ដល់ពួកគេនូវលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើង។ ប្រសិនបើអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា មានការពេញចិត្តនឹងលទ្ធផល និងវិធានការដែលបានធ្វើឡើង លេខាធិការដ្ឋាននឹងបិទសំណុំរឿង និងបញ្ជូនសំណុំរឿង (ទម្រង់ព័ត៌មានឧបទ្ទវហេតុ និងរបាយការណ៍អង្កេតឧបទ្ទវហេតុ) ទៅកាន់ HACC ដើម្បីរក្សាទុកជាឯកសារ។

៨. រាល់ពាក្យរាយការណ៍/ការតវ៉ាផ្សេងទៀតដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្ត ត្រូវបានបញ្ជូនទៅក្រុមថ្នាក់ជាតិ (ឆ្លើយតប HIVSD ឧទា. បណ្តឹងដែលបានធ្វើឡើងក្នុងប្រព័ន្ធយុត្តិធម៌) ដែលលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ខេត្ត នឹងប្រគល់សំណុំរឿងទៅលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ។

៩. លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នៅពេលទទួលបានដាក់ពាក្យរាយការណ៍/ការតវ៉ាពីលេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត សម្របសម្រួល និងចាត់តាំងសមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិសមស្រប ដើម្បីធ្វើការអង្កេត និងចាត់វិធានការ។

១០. សមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ ដែលត្រូវបានតែងតាំងធ្វើការទាក់ទងគ្រឹះស្ថាន និងជនប្រព្រឹត្តដែលត្រូវចោទប្រកាន់ ដើម្បីធ្វើការអង្កេត និងចាត់វិធានការ។ សមាជិកក្រុមឆ្លើយតប HIVSD ដែលអង្កេត បំពេញរបាយការណ៍អង្កេតឧបទ្ទវហេតុ ហើយបញ្ជូនទៅលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ។

១១. លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ ទទួលបានរបាយការណ៍អង្កេតឧបទ្ទវហេតុពីសមាជិកក្រុមឆ្លើយតប HIVSD ដែលធ្វើការអង្កេត ហើយទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាដំបូង ដើម្បីតាមដានបន្តលើលទ្ធផល និងវិធានការដែលបានធ្វើឡើង។ ប្រសិនបើអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាពេញចិត្តនឹងលទ្ធផល និងវិធានការដែលបានធ្វើឡើង លេខាធិការដ្ឋាននឹងបិទសំណុំរឿង ហើយបញ្ជូនសំណុំរឿង (ទម្រង់ព័ត៌មានឧបទ្ទវហេតុ និងរបាយការណ៍អង្កេតឧបទ្ទវហេតុ) ទៅ HACC ដើម្បីរក្សាទុកជាឯកសារ។

១២. រាល់ពាក្យពាក្យរាយការណ៍/ការតវ៉ាណាដែលមិនអាចដោះស្រាយបានដោយក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងត្រូវដាក់ជូនទៅ NAA ដើម្បីសម្របសម្រួលវិធានការជាមួយក្រសួងនិង/ឬស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ពាក្យរាយការណ៍/ការតវ៉ានោះនឹងត្រូវបានរក្សាទុកជាឯកសារដោយលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នៅក្នុងរបាយការណ៍អង្កេតឧបទ្ទវហេតុ ហើយបញ្ជូនទៅ HACC ដើម្បីរក្សាទុកជាឯកសារ។

ក្របខណ្ឌពេលវេលានៃការឆ្លើយតប



- លេខាធិការដ្ឋាននៃក្រុមឆ្លើយ HIVSD ថ្នាក់ខេត្ត ត្រូវទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីប្រមូលព័ត៌មានលម្អិតអំពីឧបទ្ទវហេតុ HIVSD ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីបានទទួលពាក្យដាក់ពាក្យរាយការណ៍/ការតវ៉ាដំបូង។
- លេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត នឹងទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់គាត់អំពីលទ្ធផលនៃការអង្កេតដំបូង និងវិធានការដែលបានធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីបានទទួលពាក្យរាយការណ៍/ការតវ៉ាដំបូង។
- ប្រសិនបើសំណុំរឿងត្រូវបានដាក់ទៅថ្នាក់ជាតិ លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីជម្រាបអំពីលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើងក្នុងរយៈពេលបីសប្តាហ៍បន្ទាប់ពីបានទទួលពាក្យរាយការណ៍/ការតវ៉ាដំបូង។
- ប្រសិនបើសំណុំរឿងនោះមិនអាចដោះស្រាយបានដោយក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ ហើយត្រូវការចំណាត់ការបន្ថែមទៀតដោយអាជ្ញាធររដ្ឋាភិបាលកម្រិតខ្ពស់ លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងជូនដំណឹងដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាអំពីលទ្ធផលនេះ ក្នុងរយៈពេលមួយខែបន្ទាប់ពីបានទទួលពាក្យរាយការណ៍/ការតវ៉ាដំបូង។

សមាសភាព និងតំណែងខុសត្រូវរបស់ក្រុមឆ្លើយតប

លេខាធិការដ្ឋានបច្ចុប្បន្ននៃ FoNPAM និង DFoNPAM នឹងដើរតួជាលេខាធិការនៃក្រុមឆ្លើយតប HIVSD។ ក្រុមឆ្លើយតប HIVSD នីមួយៗ នឹងមានតំណាងពីរូបមកពីបណ្តាញអ្នករស់នៅជាមួយមេរោគ

អេដស៍/ក្រុមប្រឈមមុខខ្ពស់ និងស្ថាប័នរដ្ឋាភិបាលនីមួយៗ ដើម្បីធានាបាននូវមុខងារប្រកបដោយប្រសិទ្ធភាព និងការឆ្លើយតបទាន់ពេលវេលា។ ក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត តែងតែជាក្រុមទំនាក់ទំនងដំបូងបំផុត ដើម្បីទទួលពាក្យរាយការណ៍/ការតវ៉ា HIVSD ទាំងអស់ និងធ្វើការអង្កេត និងចាត់វិធានការ។ ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងត្រូវធ្វើអន្តរាគមន៍ចំពោះពាក្យរាយការណ៍/ការតវ៉ា ដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្ត និងឬត្រូវការចំណាត់ការដោយអាជ្ញាធរជាតិ (ពោលគឺ បណ្តឹងដែលធ្វើឡើងតាមរយៈតុលាការ)។ ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ មានតំណាងពីរូបមកពីអង្គភាពរដ្ឋាភិបាលនិងបណ្តាញពាក់ព័ន្ធ។ សូមកត់សម្គាល់ថា សមាសភាពក្រុមឆ្លើយតបដែលបានរៀបរាប់នៅក្នុងផ្នែកនេះ ត្រូវបានប្រើជាមគ្គទេសក៏ ហើយនឹងនៅតែកែតម្រូវបានផ្អែកលើតម្រូវការចាំបាច់របស់ខេត្ត។

ក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តនីមួយៗ រួមមានតំណាងពីរូបមកពីស្ថាប័ននីមួយៗ៖ DFoNPAM (លេខាធិការដ្ឋាន) + គណៈកម្មាធិការអេដស៍ខេត្ត (ប្រធាន) + កម្មវិធីអេដស៍ និងកាមរោគខេត្ត / មន្ទីរសុខាភិបាលខេត្ត + មន្ទីរអប់រំ យុវជន និងកីឡាខេត្ត + សាលាខេត្ត និងនគរបាល។ ទំនួលខុសត្រូវរបស់សមាជិកនីមួយៗ រួមមាន៖

១) ប្រធានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត (PAC)៖
- អភិបាលខេត្តនៅក្នុងខេត្តអនុវត្ត CLM នីមួយៗ ត្រូវធ្វើជាប្រធានក្រុមឆ្លើយតបនេះ។
- រៀបចំកិច្ចប្រជុំក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តប្រចាំខែ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត និងរាយការណ៍អំពីករណីនានា។

២) លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត (DFoNPAM)៖
- ជនបង្គោលទទួលពាក្យរាយការណ៍/ការតវ៉ា HIVSD ពី CLM app។
- ទូរសព្ទទៅអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាវិញ ដើម្បីប្រមូលព័ត៌មានបន្ថែម ដើម្បីចាប់ផ្តើមការអង្កេត។
- នៅពេលដែលព័ត៌មានត្រូវបានប្រមូលរួច លេខាធិការដ្ឋាននឹងចាត់តាំងសមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តសមស្រប ដើម្បីធ្វើការអង្កេត និងចាត់វិធានការ។
- លេខាធិការដ្ឋានក៏មានទំនួលខុសត្រូវក្នុងការទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីជម្រាបអំពីលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើង។ ប្រសិនបើអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា មានការពេញចិត្តនឹងលទ្ធផលនៃការអង្កេត លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត នឹងបិទសំណុំរឿង ហើយបញ្ជូនសំណុំរឿងនោះទៅកាន់ HACC ដើម្បីរក្សាទុកជាឯកសារ។
- ប្រសិនបើអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា មិនពេញចិត្តនឹងលទ្ធផលនៃការអង្កេតទេ លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត នឹងបញ្ជូនពាក្យរាយការណ៍/ការតវ៉ា នោះទៅកាន់ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ តាមរយៈលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ។

៣) ក្នុងករណីមានការរាយការណ៍/ការតវ៉ា HIVSD ដែលធ្វើឡើងក្នុងបរិបទវិស័យអប់រំ តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នឹងដឹកនាំការអង្កេត។

៤) ក្នុងករណីមានពាក្យរាយការណ៍/ការតវ៉ា HIVSD ដែលធ្វើឡើងនៅក្នុងបរិបទថែទាំសុខភាព កម្មវិធីអេដស៍ និងកាមរោគខេត្ត និងតំណាងមន្ទីរសុខាភិបាលខេត្ត ត្រូវដឹកនាំការអង្កេត។

៥) ក្នុងករណីពាក្យរាយការណ៍/ការតវ៉ា HIVSD ដែលធ្វើឡើងនៅក្នុងសហគមន៍ និងកន្លែងធ្វើការសាលាខេត្ត និងតំណាងនគរបាល ត្រូវដឹកនាំការអង្កេត។

៦) តំណាងនគរបាល នឹងត្រូវបានតែងតាំងដើម្បីគាំទ្រការអង្កេតណាដែលត្រូវការអន្តរាគមន៍ពីមន្ត្រីអនុវត្តច្បាប់។

ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ រួមមានតំណាងពីរូបមកពីស្ថាប័ននីមួយៗ ៖ FoNPAM (លេខាធិការដ្ឋាន) + អាជ្ញាជាតិប្រយុទ្ធនឹងជំងឺអេដស៍ + មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ + ក្រសួងអប់រំ យុវជន និងកីឡា + ក្រសួងមហាផ្ទៃ និង CPN+ ដៃគូពាក់ព័ន្ធ មានទំនួលខុសត្រូវដូចខាងក្រោម ៖

១) ប្រធានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ៖

- NAA នឹងធ្វើជាប្រធានក្រុមឆ្លើយតបថ្នាក់ជាតិ។
- រាល់ពាក្យរាយការណ៍/ការតវ៉ាណាដែលមិនអាចដោះស្រាយបានដោយក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងត្រូវប្រគល់ជូនប្រធាន ដើម្បីសម្របសម្រួលវិធានការសមស្របជាមួយក្រសួង និង/ឬស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ពាក្យរាយការណ៍/ការតវ៉ានេះនឹងត្រូវបានចងក្រងជាឯកសារដោយលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ និងបញ្ជូនទៅ HACC ដើម្បីរក្សាទុកជាឯកសារ។
- បើកវគ្គសិក្សាប្រចាំត្រីមាសជាមួយក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តទាំងអស់ ដើម្បីតាមដានមើលវឌ្ឍនភាពនៃការអនុវត្ត និងរាយការណ៍អំពីសំណុំរឿង។

២) លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ (FoNPAM) ៖

- ទទួលករណីបញ្ជូនពីលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ដើម្បីអង្កេតពាក្យរាយការណ៍/ការតវ៉ា ដែលមិនអាចដោះស្រាយបាននៅថ្នាក់ខេត្ត និង/ឬត្រូវការអន្តរាគមន៍ពីអាជ្ញាធរថ្នាក់ជាតិ។
- នៅពេលករណីបញ្ជូនមកត្រូវបានទទួល លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិទទួលខុសត្រូវក្នុងការចាត់តាំងសមាជិកក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិសមស្រប ដើម្បីទាក់ទងគ្រឹះស្ថាន និងជនប្រព្រឹត្តដើម្បីធ្វើការអង្កេត និងចាត់វិធានការ។
- លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ ត្រូវទទួលខុសត្រូវចំពោះការទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាដើម្បីជម្រាបប្រាប់អំពីលទ្ធផលនៃការអង្កេត និងវិធានការដែលបានអនុវត្ត។ ប្រសិនបើអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ពេញចិត្តនឹងលទ្ធផលនៃការអង្កេត

លេខាធិការ ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងបិទសំណុំរឿង ហើយបញ្ជូនសំណុំរឿងឆ្លើយតប HIVSD ទៅ HACC ដើម្បីរក្សាទុកជាឯកសារ។

៣) ក្នុងករណីពាក្យរាយការណ៍/ការតវ៉ា HIVSD ដែលបានធ្វើឡើងក្នុងបរិបទអប់រំ តំណាងក្រសួងអប់រំ យុវជន និងកីឡា នឹងដឹកនាំការអង្កេត។

៤) ក្នុងករណីជាក់ពាក្យរាយការណ៍/ការតវ៉ា HIVSD ដែលបានធ្វើឡើងនៅក្នុងបរិបទថែទាំសុខភាព តំណាង NAA និង NCHADS នឹងដឹកនាំការអង្កេត។

៥) ក្នុងករណីជាក់ពាក្យរាយការណ៍/ការតវ៉ា HIVSD ដែលធ្វើឡើងនៅក្នុងបរិបទសហគមន៍ និងកន្លែងធ្វើការ អង្គការក្រៅរដ្ឋាភិបាល/បណ្តាញ តំណាងក្រសួងមហាផ្ទៃ នឹងដឹកនាំការអង្កេត។

ការជាក់ពាក្យរាយការណ៍/ការតវ៉ា អំពីការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ដោយប្រើ CLM

អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់អាច នឹងត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យរាយការណ៍/ការតវ៉ាអំពី HIVSD ដោយខ្លួនឯង ឬដោយមានការគាំទ្រពី OWs ប្រសិនបើចាំបាច់ ក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃដែលអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា បានដឹងអំពីទង្វើមាក់ងាយ និងការរើសអើងដែលបានចោទប្រកាន់នោះ។ ពួកគេអាចធ្វើដូច្នេះ ដោយស្កែន QR code ការស្ទង់មតិ CLM 7 ដើម្បីចូលបំពេញការស្ទង់មតិ។ បុគ្គលពាក់ព័ន្ធ (ឬដោយមានជំនួយពី OW) នឹងបំពេញការស្ទង់មតិនៅលើទូរសព្ទរបស់ពួកគេ ហើយមានជម្រើសក្នុងការដាក់ពាក្យរាយការណ៍/ការតវ៉ា ជាមួយនឹងសំណើសម្រាប់ការអង្កេត និងធ្វើបច្ចុប្បន្នភាពលើវិធានការដែលបានធ្វើឡើង។

ការទទួលពាក្យរាយការណ៍/ការតវ៉ា អំពីការមាក់ងាយ និងការរើសអើងដែលទាក់ទងនឹងមេរោគអេដស៍ និងការប្រមូលព័ត៌មានអំពីឧបទ្ទវហេតុ

លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តក្នុងខេត្តប្រតិបត្តិការ CLM គឺជាជនបង្គោលដើម្បីទទួលព័ត៌មានអំពីការឆ្លើយតប HIVSD តាមរយៈ Telegram។ នៅពេលបានទទួលការជូនដំណឹង លេខាធិការដ្ឋាននឹងទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា និងប្រមូលព័ត៌មានលម្អិតដោយប្រើទម្រង់ "ព័ត៌មានឧបទ្ទវហេតុ" ដោយជួបផ្ទាល់ ឬតាមទូរស័ព្ទ ហើយព័ត៌មាននេះនឹងត្រូវបញ្ជូនទៅកាន់សមាជិកក្រុមឆ្លើយតប HIVSD ដែលបានតែងតាំងដើម្បីធ្វើការអង្កេត និងចាត់វិធានការ ។

នៅពេលធ្វើការហៅទូរសព្ទដំបូងត្រឡប់ទៅអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាវិញ ដើម្បីប្រមូលព័ត៌មានអំពីឧបទ្ទវហេតុ លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ត្រូវ៖

១. ណែនាំខ្លួនពួកគេ តួនាទី និងក្រុមឆ្លើយតប HIVSD និងអ្វីដែលក្រុមឆ្លើយតប HIVSD អាចធ្វើបាន។

២. បញ្ជាក់ដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាថា ការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ គឺជាការប្រឆាំងនឹងរដ្ឋធម្មនុញ្ញ និងច្បាប់របស់កម្ពុជាស្តីពីការទប់ស្កាត់ និងការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍។
៣. ដោះស្រាយការភ័យខ្លាចការសងសឹកជាមុន ដោយបញ្ជាក់ឡើងវិញ និងធានាភាពសម្ងាត់ និងភាពអនាមិក និងភាពជាឯកជន។
៤. បង្ហាញដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាអំពីលំហូរនៃការឆ្លើយតប រួមទាំងពេលវេលានៃជំហានសំខាន់ៗ។
៥. បញ្ជាក់ការដាក់ពាក្យរាយការណ៍/ការតវ៉ា ត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាពាក្យរាយការណ៍/ការតវ៉ា នេះមិនទាន់បានដាក់តាមរយៈ CLM ពីមុនមកទេ ហើយថា អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា មានបំណងចង់បន្តការអង្កេត។
៦. ប្រមូលព័ត៌មានលម្អិតពីអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដោយប្រើទម្រង់ "ព័ត៌មានឧបទ្ទវហេតុ" នៅក្នុងឧបសម្ព័ន្ធទី១។
៧. លេខាធិការដ្ឋានក្រុមឆ្លើយតបនឹង HIVSD ត្រូវធានាចំពោះអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាសារជាថ្មីអំពីភាពសម្ងាត់នៅក្នុងដំណើរការសម្ភាសន៍ទាំងមូល។
៨. ជម្រាបដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាអំពីវិធានការដែលអាចធ្វើឡើង (សូមមើលផ្នែកស្តីពីវិធានការក្រុមឆ្លើយតបខាងក្រោម)។
៩. ផ្តល់ការគាំទ្រពីមិត្តភក្តិ និង/ឬការគាំទ្រផ្នែកច្បាប់ ដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា។
១០. អញ្ជើញអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ឱ្យចូលរួមក្នុងសិក្ខាសាលានៅពេលខាងមុខស្តីពីការការពារវិជ្ជមាន និង/ឬវេទិកាអ្នករស់នៅជាមួយមេរោគអេដស៍/ក្រុមប្រឈម ដោយបញ្ជូនលេខទំនាក់ទំនងរបស់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ទៅកាន់ CPN+ ដោយមានការយល់ព្រមពីគាត់។
១១. អរគុណដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាដែលបានចំណាយពេលវេលា ហើយដម្រាបប្រាប់គាត់អំពីជំហានបន្ទាប់ លេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD នឹងទូរសព្ទមកវិញដើម្បីផ្តល់លទ្ធផលអំពីការអង្កេត និងសកម្មភាពដែលបានធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីបានដាក់ពាក្យរាយការណ៍/ការតវ៉ាដំបូង។
១២. សួរអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា តើគាត់មានសំណួរអ្វីឬទេ និងបញ្ចប់ការហៅ/ការជួប។

វិធានការក្រុមឆ្លើយតប

ក្រុមឆ្លើយតប HIVSD ប្រសិនបើឃើញថា ឧបទ្ទវហេតុ HIVSD ពិតជាបានកើតឡើងតាមការចោទប្រកាន់ក្នុងពាក្យរាយការណ៍/ការតវ៉ានឹង៖

១. ទីមួយ ណែនាំគ្រឹះស្ថាន និង/ឬជនប្រព្រឹត្ត ឱ្យចាត់វិធានការកែតម្រូវស្ថានភាពដែលជំរុញឱ្យមានពាក្យរាយការណ៍/ការតវ៉ា HIVSD។
២. ទីពីរ ផ្តល់ប្រឹក្សាយោបល់ដល់ជនប្រព្រឹត្ត និងតម្រូវឱ្យជននោះទទួលការបណ្តុះបណ្តាលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ បទបញ្ជា និងគោលការណ៍ណែនាំ ជាពិសេសទាក់ទងនឹង HIVSD។
៣. នៅពេលមានការរំលោភជាបន្តបន្ទាប់ទៅលើច្បាប់ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ដោយបុគ្គល/ស្ថាប័នដដែល ក្រុមឆ្លើយតប HIVSD អាចណែនាំឱ្យបុគ្គល ឬគ្រឹះស្ថាននោះទទួលវិធានការវិនិយស្របតាមច្បាប់។
៤. លេខាធិការដ្ឋាននៃក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្តនីមួយៗ (និងលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ សម្រាប់ការអង្កេត និងវិធានការថ្នាក់ជាតិ) ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា អំពីវិធានការដែលបានធ្វើឡើងទាក់ទងនឹងពាក្យរាយការណ៍/ការតវ៉ា និងសិទ្ធិរបស់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ក្នុងការបញ្ជូនសំណុំរឿងទៅថ្នាក់ជាតិ (ថ្នាក់ជាតិ ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ) ឬសម្រាប់ដំណោះស្រាយតាមផ្លូវច្បាប់សមស្របណាមួយផ្សេងទៀត ក្នុងករណីអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា មិនពេញចិត្តនឹងវិធានការដែលបានធ្វើឡើង។
៥. នៅពេលសម្រេចចិត្តលើពាក្យរាយការណ៍/ការតវ៉ាណាមួយ ក្រុមឆ្លើយតប HIVSD ត្រូវផ្តល់ហេតុផលខ្លីៗជាលាយលក្ខណ៍អក្សរសម្រាប់ការសម្រេចចិត្តនោះដល់បុគ្គល និង/ឬគ្រឹះស្ថានដែលពាក់ព័ន្ធ និងភាគីពាក់ព័ន្ធទាំងអស់នៃពាក្យរាយការណ៍/ការតវ៉ា ក្នុងរយៈពេលដប់ថ្ងៃ គិតចាប់ពីថ្ងៃសម្រេចចិត្ត។

ការតាមដានបន្តជាមួយពាក្យរាយការណ៍/ការតវ៉ា

ក្នុងករណីភាគច្រើនបំផុត នៅពេលដែលពាក្យរាយការណ៍/ការតវ៉ា ត្រូវបានដោះស្រាយរួច លេខាធិការក្រុមឆ្លើយតប HIVSD ត្រូវទាក់ទងអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា ដើម្បីជម្រាបប្រាប់អំពីលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើងក្នុងអំឡុងពេលនៃការឆ្លើយតបដែលបានកំណត់ (សូមមើល "គម្រោងពេលឆ្លើយតប") ។ នៅពេលធ្វើការហៅទូរសព្ទត្រឡប់ទៅអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា លេខាធិការក្រុមឆ្លើយតប HIVSD ត្រូវ៖

១. បញ្ជាក់ថា ពាក្យរាយការណ៍/ការតវ៉ា ត្រូវបានធ្វើឡើងដោយអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា។
២. ផ្តល់ឱ្យអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា នូវលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើង។
៣. ជម្រាបដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា អំពីជម្រើសរបស់ពួកគេសម្រាប់ជំហានបន្ទាប់ករណីសំណុំរឿង ប្រសិនបើគាត់ពេញចិត្តជាមួយលទ្ធផល ឬដាក់ពាក្យរាយការណ៍/ការតវ៉ាទៅថ្នាក់ជាតិ និង/ឬ ដំណោះស្រាយផ្លូវច្បាប់សមស្របណាមួយផ្សេងទៀត។

៤. អញ្ជើញអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាឱ្យចូលរួមសិក្ខាសាលានៅពេលខាងមុខស្តីពីការការពារវិជ្ជមាន និង/ឬវេទិកាអ្នករស់នៅជាមួយមេរោគអេដស៍/ក្រុមប្រឈម ដោយបញ្ជូនលេខទំនាក់ទំនងរបស់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ាទៅ CPN+ ដោយមានការយល់ព្រមពីអ្នកដាក់ពាក្យរាយការណ៍/ការតវ៉ា។
៥. ផ្តល់ការគាំទ្រពីមិត្តភក្តិ និងភ្ជាប់ជាមួយអ្នកអប់រំមេរោគអេដស៍ (HIV OW)។
៦. ថ្លែងអំណរគុណដល់អ្នកដាក់ពាក្យរាយការណ៍/ការតវ៉ានិងបញ្ចប់ការសន្ទនាតាមទូរសព្ទ/ការជួប។

ភាពសម្ងាត់ និងការភ័យខ្លាចចំពោះការសងសឹក

ការភ័យខ្លាចអំពីការសងសឹក ការព្រួយបារម្ភអំពីផលវិបាកអវិជ្ជមាននៃការដាក់ពាក្យរាយការណ៍/ការតវ៉ាប្រឆាំងនឹងគ្រឹះស្ថានឬបុគ្គល គឺជាឧបសគ្គដ៏សំខាន់មួយចំពោះយន្តការរាយការណ៍និងឆ្លើយតបដោយជោគជ័យ ហើយត្រូវតែដោះស្រាយដោយការយកចិត្តទុកដាក់ និងពង្រឹងភាពសម្ងាត់។ លើសពីនេះទៀត ភាពសម្ងាត់មានសារៈសំខាន់ណាស់ក្នុងការកសាងទំនុកចិត្ត និងការជឿទុកចិត្តរបស់សហគមន៍លើការរាយការណ៍ និងយន្តការឆ្លើយតប HIVSD និងការឆ្លើយតបនឹងមេរោគអេដស៍របស់កម្ពុជា។ រាល់ព័ត៌មានផ្ទាល់ខ្លួនទាំងអស់ដែលប្រមូលបានត្រូវរក្សាទុកជាសម្ងាត់ និងអាចចូលមើលបានដោយបុគ្គលិកដែលមានការអនុញ្ញាតតែប៉ុណ្ណោះ។ អ្នកចុះអប់រំផ្ទាល់ ដែលជួយអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ ដើម្បីបំពេញការស្នង់មតិ CLM ក៏ត្រូវការពារភាពជាឯកជន និងភាពសម្ងាត់របស់អតិថិជនផងដែរ។ ដើម្បីលើកទឹកចិត្តដល់ការរាយការណ៍ និងការស្វែងរកការឆ្លើយតប HIVSD សេចក្តីថ្លែងបដិសេធនៅក្នុងការស្នង់មតិ CLM 7 ត្រូវបានដាក់បញ្ចូលដើម្បីបញ្ជាក់ពីការការពារភាពជាឯកជន និងភាពសម្ងាត់របស់បុគ្គល។

ការផ្សព្វផ្សាយយន្តការរាយការណ៍ និងឆ្លើយតបចំពោះការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៍

ការរាយការណ៍ និងយន្តការឆ្លើយតប HIVSD ត្រូវផ្សព្វផ្សាយរួមគ្នាជាមួយ CLM ដែលមានស្រាប់។ សមាគមអ្នករស់នៅជាមួយមេរោគអេដស៍/ក្រុមប្រឈម CSOs, CBOs និងបណ្តាញនានា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានសកម្មនូវ CLM និងយន្តការរាយការណ៍ និងឆ្លើយតប HIVSD រៀងរាល់ត្រីមាសតាមរយៈបណ្តាញរបស់ពួកគេ។ សកម្មភាពនេះអាចត្រូវបានធ្វើដោយការផលិតសម្ភាររូបភាពដើម្បីផ្សព្វផ្សាយ CLM និងយន្តការរាយការណ៍ និងឆ្លើយតប តាមប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា Facebook និង TikTok រួមជាមួយការផ្សព្វផ្សាយដល់ក្រុមគោលដៅនៅក្នុងខេត្តប្រតិបត្តិការ CLM ផងដែរ។ ម៉្យាងទៀត យន្តការរាយការណ៍ និងឆ្លើយតប HIVSD អាចត្រូវបានផ្សព្វផ្សាយតាមរយៈការចែកចាយសម្ភារ IEC នៅតាមព្រឹត្តិការណ៍ និងស្ថាប័ន/គ្រឹះស្ថាននានា។ ការរចនាសម្ភារផ្សព្វផ្សាយ ត្រូវមាន៖

- ការអង្កេត CLM 7 QR Code
- ការពិពណ៌នាខ្លីៗអំពី CLM និង យន្តការរាយការណ៍ និងឆ្លើយតប HIVSD
- សង្កត់ធ្ងន់លើភាពសម្ងាត់ និងការឆ្លើយតបទាន់ពេលវេលា
- សេចក្តីថ្លែងការណ៍សកម្មភាព ដើម្បីស្នែនកូដ QR ស្នង់មតិ

ការកត់ត្រាទុកជាឯកសារ និងការរក្សាកំណត់ត្រា

នៅពេលទទួលបានពាក្យរាយការណ៍/ការតវ៉ា HIVSD លេខាធិការក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ត្រូវបង្កើតឯកសារសំណុំរឿងមួយសម្រាប់ពាក្យរាយការណ៍/ការតវ៉ានីមួយៗ និងប្រើ "ទម្រង់ព័ត៌មានឧបទ្វវហេតុ" (សូមមើលឧបសម្ព័ន្ធទី១) ដើម្បីហៅទូរសព្ទមកវិញ ដើម្បីប្រមូលព័ត៌មានលម្អិតសម្រាប់ការអង្កេតក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីទទួលបានព័ត៌មានអំពីឧបទ្វវហេតុ។ ឯកសារសំណុំរឿងនេះក៏ត្រូវមាន "របាយការណ៍អង្កេតឧបទ្វវហេតុ" ផងដែរ ដែលផ្តល់ព័ត៌មានអំពីវឌ្ឍនភាព និងលទ្ធផលនៃការអង្កេត និងវិធានការដែលបានធ្វើឡើង ហើយត្រូវបំពេញដោយសមាជិកក្រុមឆ្លើយតប HIVSD។ នៅពេលបិទសំណុំរឿង លេខាធិការក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ឬថ្នាក់ជាតិ ត្រូវបញ្ជូនសំណុំរឿងទៅ HACC ដើម្បីរក្សាទុកជាឯកសារ ព្រោះថា បច្ចុប្បន្ន HACC គឺជាលេខាធិការដ្ឋាននៃ DFoNPAM និង FoNPAM ដែលរក្សាទុករាល់កំណត់ត្រា CLM ទាំងអស់។

ការតម្រង់ទិស និងការកសាងសមត្ថភាពក្រុមឆ្លើយតប HIVSD

ការតម្រង់ទិសអំពីយន្តការរាយការណ៍និងឆ្លើយតប HIVSD និងការបណ្តុះបណ្តាលកសាងសមត្ថភាពរបស់យន្តការនេះ នឹងត្រូវផ្តល់ជូនដល់ក្រុមឆ្លើយតប និងសមាជិកទាំងអស់នៃ DFoNPAM និង FoNPAM មុនពេលអនុវត្តការងាររបស់ពួកគេ។ ការបណ្តុះបណ្តាល នឹងរួមបញ្ចូលការតម្រង់ទិស CLM និងយន្តការឆ្លើយតប និងគ្របដណ្តប់លើព័ត៌មាននៅក្នុងគោលការណ៍ណែនាំនេះ។ បន្ទាប់មក វគ្គបណ្តុះបណ្តាលបំប៉នអំពីយន្តការរាយការណ៍និងឆ្លើយតប HIVSD ជាបន្តបន្ទាប់មកទៀត នឹងត្រូវបានធ្វើឡើងរៀងរាល់កន្លះឆ្នាំម្តង ហើយនឹងត្រូវរួមបញ្ចូលជាមួយវគ្គបំប៉នទិន្នន័យ CLM ដោយរៀបចំជាកញ្ចប់បណ្តុះបណ្តាលពេញមួយថ្ងៃ។

ការត្រួតពិនិត្យតាមដានក្រុមឆ្លើយតបការមាក់ងាយនិងការរើសអើងទាក់ទងនឹងមេរោគអេដស៍ និងការប្រើប្រាស់ទិន្នន័យ

ដោយសារយន្តការឆ្លើយតប HIVSD ត្រូវបានដាក់បញ្ចូលទៅក្នុង CLM ដែលមានស្រាប់ យន្តការនេះត្រូវបានត្រួតពិនិត្យតាមដានតាមរយៈប្រព័ន្ធត្រួតពិនិត្យដូចគ្នាសម្រាប់ CLM។ ក្រុមឆ្លើយតប HIVSD ថ្នាក់ខេត្ត ក្នុងខេត្តប្រតិបត្តិការ CLM នីមួយៗ នឹងរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីតាមដានមើលវឌ្ឍនភាពនៃការអនុវត្ត និងរាយការណ៍អំពីសំណុំរឿង។ ក្រុមឆ្លើយតប HIVSD ថ្នាក់ជាតិ នឹងជួបប្រជុំប្រចាំត្រីមាសតាមបែបនិម្មិត តែជាមួយសមាជិកក្រុមឆ្លើយតប HIVSD ទាំងអស់ ដើម្បីតាមដានវឌ្ឍនភាព

ផ្លាស់ប្តូរគំនិត បង្ហាញពីការអនុវត្តល្អបំផុត/ជោគជ័យ ពិភាក្សាករណីដែលលំបាក និងផ្តល់ការអភិបាលដល់សមាជិកក្រុមឆ្លើយតប HIVSD។

របាយការណ៍ HIVSD នឹងត្រូវដាក់បញ្ចូលទៅក្នុងម៉ាស៊ីនមេប្រមូលមតិត្រឡប់ CLM (CLM feedback loops server) តាមរយៈយន្តការស្តង់ដារ CLM ហើយព័ត៌មានត្រូវបានប្រមូលដោយ HACC ហើយដាក់ចូលទៅក្នុងឧបករណ៍បណ្ណពិន្ទុសហគមន៍ក្រុមប្រឈមឌីជីថល ដែលត្រូវប្រើប្រាស់ដោយភាគីពាក់ព័ន្ធសំខាន់ៗជាច្រើន ជាពិសេស DFoNPAM និង FoNPAM ដើម្បីចែករំលែកជាមួយអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងៗទៀត អ្នកផ្តល់សេវា អ្នកមានករណីយកិច្ច ដើម្បីចាត់វិធានការលើរបកគំហើញនៅក្នុងឧបករណ៍បណ្ណពិន្ទុសហគមន៍ក្រុមប្រឈម។ សំណុំឯកសារដែលដាក់ជូនដោយលេខាធិការដ្ឋានក្រុមឆ្លើយតប HIVSD ត្រូវបានរក្សាទុកនៅ HACC ហើយព័ត៌មានត្រូវបានប្រើប្រាស់ដើម្បីដាក់បញ្ចូលក្នុងទិន្នន័យដែលប្រមូលបានតាមរយៈ CLM។

ឧបសម្ព័ន្ធទី ១ – ទម្រង់ព័ត៌មានឧបទ្ធវហេតុ

បុគ្គលដែលមានបទពិសោធន៍ ឬបានឃើញឧបទ្ធវហេតុ HIVSD អាចប្រើទម្រង់នេះដើម្បីដាក់ពាក្យរាយការណ៍/ការតវ៉ាដោយប្រើយន្តការឆ្លើយតប HIVSD។ បណ្តាញក៏អាចប្រើទម្រង់នេះបានដែរ ប្រសិនបើសមាជិករបស់ពួកគេមករកពួកគេ ហើយសុំឱ្យពួកគេជួយដើម្បីដាក់ពាក្យរាយការណ៍/ការតវ៉ HIVSD ដែលបានកើតឡើងចំពោះពួកគេ។ អ្នកគួរតែកត់ត្រាទុកជាឯកសារនូវឧបទ្ធវហេតុ HIVSD ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីវាកើតឡើង ឬនៅក្នុងគម្រោងពេលឆ្លើយតបដែលមានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំស្តីពីការអនុវត្តយន្តការ និងការឆ្លើយតប HIVSD។ សូមធ្វើរបាយការណ៍ដាច់ដោយឡែកមួយសម្រាប់ពាក្យរាយការណ៍/ការតវ៉ានីមួយៗ។

កាលបរិច្ឆេទនៃរបាយការណ៍ (ថ្ងៃ ខែ ឆ្នាំ):

លេខទូរស័ព្ទទំនាក់ទំនង ៖ ដើម្បីភ្ជាប់ជាមួយរបាយការណ៍អង្កេតឧបទ្ធវហេតុសម្រាប់ពាក្យរាយការណ៍/ការតវ៉ាតែមួយ

បុគ្គលដែលផ្តល់របាយការណ៍ ៖

តើអ្នកគឺជាបុគ្គលដែលត្រូវបានគេរំលោភសិទ្ធិមែនទេ?

បាទ/ចាស៎_____ ទេ_____

តើអ្នកគឺជាសាក្សីដែលបានឃើញការរំលោភសិទ្ធិឬទេ?

បាទ/ចាស៎_____ ទេ_____

ការយល់ព្រម ៖ ប្រសិនបើអ្នកបំពេញទម្រង់នេះសម្រាប់អ្នកផ្សេង សូមសួរពួកគេថា តើពួកគេយល់ព្រមឱ្យអ្នកកត់ត្រាឧបទ្ទវហេតុ HIVSD ដែលពួកគេបានជួបប្រទះដែរឬទេ។ ប្រសិនបើពួកគេយល់ព្រម សូមបញ្ជាក់ពីពេលវេលា និងកាលបរិច្ឆេទដែលនៃការផ្តល់ការយល់ព្រម (ប្រសិនបើតាមរយៈទូរសព្ទ) ឬសុំឱ្យពួកគេចុះហត្ថលេខា ឬផ្តល់ស្នាមមេដៃនៅទីនេះ (ប្រសិនបើជួបផ្ទាល់)៖

ការយល់ព្រមជាលាយលក្ខណ៍អក្សរ/ផ្ទាល់មាត់របស់អ្នកជាក់ពាក្យរាយការណ៍/ការតវ៉ាផ្តល់ឱ្យនៅពេលវេលា: កាលបរិច្ឆេទ៖

តើអ្នកចង់លាក់អត្តសញ្ញាណក្នុងអំឡុងពេលធ្វើការអង្កេតឬទេ?

ហត្ថលេខា ឬស្នាមមេដៃ៖

កាលបរិច្ឆេទ៖ តើឧបទ្ទវហេតុនោះបានកើតឡើងនៅពេលណា? (ថ្ងៃ ខែ និងឆ្នាំ)

ពេលវេលា៖ តើឧបទ្ទវហេតុនោះបានកើតឡើងនៅម៉ោងប៉ុន្មាន? (បើមិនប្រាកដពីពេលវេលា តើវាកើតឡើងនៅពេលព្រឹក ពេលរសៀល ពេលល្ងាច ពេលយប់ ឬយូរមកមកហើយ?)

ឈ្មោះគ្រឹះស្ថាន៖ តើវាបានកើតឡើងនៅឯណា?

ទីកន្លែង៖ តើគ្រឹះស្ថាននោះមានទីតាំងនៅឯណា? (ទីក្រុង ភូមិ ស្រុក តំបន់/ភូមិភាគ)

ប្រភេទនៃគ្រឹះស្ថាន៖ តើគ្រឹះស្ថាននោះគឺជាអ្វី? (គ្លីនិក សាលារៀន សកលវិទ្យាល័យ ទីកន្លែងធ្វើការ អាជីវកម្ម កោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។)

ប្រភេទនៃសេវាកម្ម៖ ហេតុអ្វីបានជាអ្នកទៅគ្រឹះស្ថាននោះ?

ជនប្រព្រឹត្ត៖ តើនរណាជាអ្នកប្រព្រឹត្តអំពើ HIVSD?

ឈ្មោះ៖

មុខតំណែង៖ ប្រសិនបើមិនស្គាល់ឈ្មោះ សូមពណ៌នាបុគ្គលនោះ (អាយុ កម្ពស់ ទម្ងន់ ពណ៌សក់ សញ្ញាសម្គាល់លើខ្លួនប្រាណ លក្ខណៈរាងកាយ។ល។)

ពណ៌នា៖ តើមានអ្វីខ្លះកើតឡើងមុនពេលឧបទ្ទវហេតុ HIVSD បានកើតឡើង?

តើមានអ្វីខ្លះបានកើតឡើងនៅពេលដែលឧបទ្ទវហេតុ HIVSD កើតឡើង? ចូររៀបរាប់លម្អិត៖ តើបុគ្គលនោះបានធ្វើអ្វីខ្លះ? តើគាត់បាននិយាយអ្វីខ្លះ? តើអ្នកបានឆ្លើយតបយ៉ាងដូចម្តេច?

កត្តាជំរុញ៖ ហេតុអ្វីបានជាអ្នកគិតថា រឿងនេះកើតឡើង? អ្នកអាចជ្រើសរើសចម្លើយជាច្រើន។ ចូរគូសប្រអប់ទាំងឡាយខាងក្រោម។

ពីព្រោះខ្ញុំ៖	☐
រស់នៅជាមួយមេរោគអេដស៍	
បុរសដែលរួមភេទជាមួយបុរស	
អ្នកបំផ្លែងភេទ	
មិនបានធ្វើសកម្មភាព ឬស្លៀកពាក់ដូចបុរស ឬស្ត្រីធម្មតា	
អ្នកប្រើគ្រឿងញៀន	
អ្នកធ្វើការក្នុងសេវាកម្មាន្ត	
រស់នៅជាមួយពិការភាព	
ផ្សេងទៀត ចូរពន្យល់៖	

ហេតុអ្វីបានជាអ្នកគិតថា វាកើតឡើងដោយសារហេតុផលទាំងនេះ? ឧទាហរណ៍ តើបុគ្គលនោះប្រើពាក្យ ឬភាសាជាក់លាក់ណាមួយឬទេ? តើបុគ្គលនោះគ្រាន់តែដឹង ឬគិតអ្វីមួយអំពីអ្នក ដែលអាចបណ្តាលឱ្យគាត់ប្រព្រឹត្តបែបនោះ (មានន័យថា អ្នកកំពុងរស់នៅជាមួយមេរោគអេដស៍ ជាអ្នករកស៊ីផ្លូវភេទ ជាបុរសរួមភេទជាមួយបុរស ឬជាអ្នកបំផ្លែងភេទ)?

ផលវិបាក និងសកម្មភាពតាមជាន់បន្ត

របួសផ្លូវកាយ៖ តើឧបទ្ទវហេតុនេះបណ្តាលឱ្យមានរបួសរាងកាយ គ្រោះថ្នាក់ ឬឈឺចាប់ដែរឬទេ? បើមែន តើអ្វីខ្លះ?

ការព្យាបាល៖ តើអ្នកត្រូវការការថែទាំសុខភាពបន្ថែមទៀតដោយសារតែអ្វីដែលបានកើតឡើងដែរឬទេ? បើបាទ/ចាស៎ តើត្រូវការការថែទាំអ្វីខ្លះ?

តើអ្នកត្រូវការស្វែងរកការថែទាំសុខភាពបន្ថែមទៀតឬទេ? បើបាទ/ចាស៎ ចូរពន្យល់នៅឯណា ការថែទាំអ្វី និងអ្នកណាជាអ្នកផ្តល់ការព្យាបាល។

ប៉ះពាល់ដល់ផ្លូវចិត្ត៖ តើឧបទ្ទវហេតុនោះបណ្តាលឱ្យមានការឈឺចាប់អារម្មណ៍ ឬផ្លូវចិត្តដែរឬទេ? បើបាទ/ចាស៎ សូមពណ៌នា ។

ការថែទាំ និងជំនួយផ្លូវចិត្ត៖ តើអ្នកត្រូវការការថែទាំ និងជំនួយផ្លូវចិត្តក្រោយកើតឧបទ្ទវហេតុដែរឬទេ? បើត្រូវការ តើត្រូវការការថែទាំអ្វីខ្លះ?

រាយការណ៍៖ ឧបទ្ទវហេតុនេះត្រូវបានគេរាយការណ៍ប្រាប់នរណាដែរឬទេ? ប្រសិនបើបាទ/ចាស ចូរពណ៌នា អ្នកណា នៅពេលណា ដោយវិធីណា។

ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ៖ តើមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុមកលើអ្នកដែរឬទេ? បើមាន ចូរពណ៌នា។

ផលប៉ះពាល់គ្រួសារ៖ តើមានផលប៉ះពាល់លើគ្រួសាររបស់អ្នកដែរឬទេ? បើមាន ចូរពណ៌នា។

ផលប៉ះពាល់សង្គម៖ តើមានផលប៉ះពាល់លើជីវិតផ្ទាល់ខ្លួន ឬជីវិតសង្គមរបស់អ្នកដែរឬទេ? បើមាន ចូរពណ៌នា។

ផលប៉ះពាល់លើការងារ៖ តើមានផលប៉ះពាល់លើការងារឬមុខរបររបស់អ្នកដែរឬទេ? បើបាទ/ចាស ចូរពណ៌នា។

ផលប៉ះពាល់ផ្សេងទៀត៖ តើមានផលប៉ះពាល់អ្វីផ្សេងទៀតឬទេ? បើបាទ/ចាស ចូរពណ៌នា។

ភស្តុតាង៖ តើមានឯកសារ រូបថត ខ្សែអាត់សំឡេង ឬខ្សែអាត់វីដេអូ (ដូចជា ខ្សែអាត់ការមើ៉ាសុវត្ថិភាព) ដែលបង្ហាញអំពីអ្វីដែលបានកើតឡើង ឬបង្ហាញផ្នែកណាមួយដែលបានកើតឡើងដែរឬទេ? បើបាទ/ចាស ចូររៀបរាប់នៅទីនេះ។ រក្សាទុកឯកសារទាំងនេះជាមួយគ្នានៅកន្លែងមួយដែលមានសុវត្ថិភាព។ ប្រសិនបើអាចធ្វើបាន សូមធ្វើថតចម្លង ហើយរក្សាទុកឯកសារទាំងនេះជាមួយរបាយការណ៍នេះ។

ឯកសារអាចរួមមានឯកសារអ្នកជំងឺ វិក្កយបត្រចំណាយលើការព្យាបាល កស្តុតាងដែលបង្ហាញថាអ្នកបានជួបជាមួយអ្នកផ្តល់សេវាថែទាំសុខភាពជាក់លាក់ម្នាក់ និងវេជ្ជបញ្ជា។ ប្រមូលយកសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរពីសាក្សី ប្រសិនបើអាច។ ប្រសិនបើអ្នករងរបួសរាងកាយ សូមថតរូបរបួសរបស់អ្នកផង។ ប្រសិនបើគ្រោះថ្នាក់ផ្លូវកាយ និងផ្លូវចិត្តនៅតែបន្តក្នុងរយៈពេលមួយឆ្នាំ សូមរក្សាទុកកំណត់ត្រា ឬសៀវភៅកំត់ហេតុប្រចាំថ្ងៃអំពីស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នក។

ឧបសម្ព័ន្ធទី ២ – រចាយការណ៍អង្កេត HIVSD

កាលបរិច្ឆេទនៃការបើកការអង្កេត៖

លេខទូរសព្ទទំនាក់ទំនង៖ ដើម្បីភ្ជាប់ជាមួយទម្រង់ព័ត៌មានឧបទ្ទវហេតុសម្រាប់ពាក្យបណ្តឹងតែមួយ។

ឈ្មោះអ្នកអង្កេត៖

មុខតំណែងអ្នកអង្កេត៖ ក្រុមឆ្លើយតប HIVSD មកពីកម្រិតណា? (ថ្នាក់ខេត្ត ឬថ្នាក់ជាតិ) និងខេត្តមួយណា?

ឈ្មោះ តួនាទី និងគ្រឹះស្ថានរបស់ជនជាប់ចោទ៖

គម្រោងពេលសម្ភាសន៍៖ ដាក់បញ្ចូលកាលបរិច្ឆេទ និងពេលវេលានៃការសម្ភាសន៍ ទីតាំងសម្ភាសន៍ ឈ្មោះបុគ្គលគ្រប់រូបដែលមានវត្តមាន។ ភ្ជាប់កំណត់ត្រាសម្ភាសន៍។

សង្ខេបការអង្កេត និងលទ្ធផល ៖

ប្រភពច្បាប់ដែលមានជាធរមាន៖ (ពោលគឺ ច្បាប់ស្តីពីការទប់ស្កាត់ និងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ រដ្ឋធម្មនុញ្ញកម្ពុជា)

ចំណាត់ការលើជនជាប់ចោទ និង/ឬ គ្រឹះស្ថាន៖

កាលបរិច្ឆេទនៃការជូនដំណឹងអំពីវិធានការលើពាក្យរាយការណ៍/ការតវ៉ា ដែលបានធ្វើឡើង៖

កាលបរិច្ឆេទដែលជនជាប់ចោទត្រូវបានជូនដំណឹងអំពីវិធានការដែលនឹងត្រូវធ្វើ៖

ការសន្ទនាតាមដានបន្តផ្សេងទៀតក្រោយពេលអង្កេត៖ រួមទាំងកាលបរិច្ឆេទ ឈ្មោះ និងប្រធានបទនៃការពិភាក្សា។ ភ្ជាប់កំណត់ហេតុកិច្ចប្រជុំដែលពាក់ព័ន្ធ។

កាលបរិច្ឆេទនៃការបិទការអង្កេត៖

ឧបសម្ព័ន្ធទី ៣ – ព័ត៌មានទំនាក់ទំនងនៃអង្គការជំនួយផ្នែកច្បាប់

Legal Aid of Cambodia (LAC)

#57-59 St. 516, Toul Sangke, Russey Keo, Phnom Penh

Phone: (+855) 023 864 201/202, 012 385 155, 092 982 028, 012 385 155

Fax: (+855) 023 864 203

E-mail: reception@lac.org.kh; lacadmin@online.com.kh

Website: www.lac.org.kh

LAC Branches:

- **Battambang Province:** #463, Group 12, Kamkor Village, Svaypor Commune, Battambang Town, Battambang Province

  Phone: (+855) 012 284 047

- **Siem Reap Province:** #0702, Group 11, Phoum Banteay Chas, Sangkat Slor Kram, Siem Reap Town, Siem Reap Province

  Phone: (+855) 012 469 694

- **Kampong Thom Province**: Phum Kdey, Sangkat Prey Tahou, Steung Sen Town, Kampong Thom Province

  Phone: (+855) 081 597 308

Cambodia Human Rights Action Committee (CHRAC)

#9Eo, Street 330, Sangkat Boeung Kengkang III, Khan Chamkarmorn, Phnom Penh

Phone: (+855) 023 301415, 023 305 609

Fax: (+855) 023 218 759

Email: chrac@forum.org.kh, chracsecretariat@yahoo.com

Website: http://www.chrac.org/kh/index.php

Cambodia League for the Promotion and Defence of Human Rights (LICADHO)

#16 St. 99, Boeung Trabek, Phnom Penh

P.O. Box 499, Phnom Penh

Phone: (+855) 023 727 102 or 023 216 602

Fax: (+855) 023 727 102 or 023 217 626

Email: contact@licadho-cambodia.org

Website: http://www.licadho-cambodia.org/).

LICADHO Branches:

- **Banteay Meanchey:** Village 3, Preah Punlea Commune, Serei Saophoan Municipality, Banteay Meanchey Province
  Phone: (+855) 054 958 861

- **Battambang:** #312, Group 21, Kampong Krabei Village, Svay Por Commune, Battambang Municipality, Battambang Province
  Phone: (+855) 053 952 828

- **Kampong Cham:** Group 4, Village 6, Veal Vong Commune, Kampong Cham Municipality, Kampong Cham Province

  Phone: (+855) 042 941 464

- **Kampong Chhnang:** Street #2, Village 2, Khsam Commune, Kampong Chhnang Municipality, Kampong Chhnang province.

  Phone: (+855) 026 988 637

- **Kampong Speu:** Lot B4, National Road 4, Peanichakam Village, Roka Thom Commune, Chbar Mon Municipality, Kampong Speu province
  Phone: (+855) 025 987 220

- **Kampong Thom:** #254, Group 44, Kampong Thom Village, Kampong Rotes Commune,

Stueng Saen Municipality, Kampong Thom Province

Phone: (+855) 062 961 292

- **Kampot:** #78, Muoy Ussphea Village, Kampong Kandal Commune, Kampot Municipality, Kampot Province

  Phone: (+855) 033 932 663

- **Koh Kong:** Village 2, Smach Meanchey Commune, Khemara Phoumin Municipality, Koh Kong Province

  Phone: (+855) 035 936 116

- **Pursat:** Morn Che Village, Prey Nhi Commune, Pursat Municipality, Pursat Province

  Phone: (+855) 052 951 496

- **Ratanakkiri:** #503, street Eo053, 7 Makara Village, Banlung Commune, Banlung Municipality, Ratanakiri Province

  Phone: (+855) 066 888 558

- **Siem Reap:** #459, Dok Por Village, Slarkram Commune, Siem Reap Municipality, Siem Reap Province

  Phone: (+855) 063 964 066

- **Sihanoukville:** Road Ek Reach, Bei Village, Pir Commune, Preah Sihanouk Municipality, Preah Sihanouk Province

  Phone: (+855) 034 933 716

- **Svay Rieng:** Rong Banle Village, Svay Rieng Commune, Svay Rieng Municipality, Svay Rieng Province

  Phone: (+855) 044 945 833

The Cambodian Human Rights and Development Association (ADHOC)

No. 3, Street 158 (Oukghna Troeung Kang),
Sangkat Boeung Raing, Khan Daun Penh,
Phnom Penh
P.O. Box: 1024, Phnom Penh

Phone: (+855) 023 218 653, 023 990 544
Fax: (+855) 023 217 229
E-mail: adhoc@forum.org.kh

Website: http://www.adhoc-cambodia.org/

The Cambodia Center for Human Rights (CCHR)

#798, St.99, Boeng Trabek, Chamkarmon,
P.O.Box: 1506, Phnom Penh

Phone: (+855) 023 726 901

Hotline: (=855) 017 505 050

Fax: (+855) 023 726 902

Email : info@cchrcambodia.org

Website:
http://cchrcambodia.org/index.php?lang=khm